# ១. សេចក្តីផ្តើម

១. ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅតាមបណ្តាប្រទេសមួយចំនួននៅលើពិភពលោក ក្នុងដំណាក់កាលដំបូង ជានិច្ចជាកាលតែងតែប៉ះពាល់លើធនធានធម្មជាតិ ដែលជាប្រភពធនធានដ៏សំខាន់ សំរាប់ទ្រទ្រង់ជីវិតសត្វលោក។ ដោយឡែកសំរាប់ប្រទេសកម្ពុជា ក៏បានចាប់ផ្តើមលើការធ្វើអាជីវកម្មធនធានព្រៃឈើតាមរយៈរូបភាពព្រៃសម្បទាន ហើយនិងការកាប់រានពង្រីកដីធ្វើកសិកម្មជាបន្តបន្ទាប់។ ការពង្រីកដីដើម្បីដាំដំណាំកសិកម្ម និងដំណាំឧស្សាហកម្មនេះត្រូវបានអនុវត្តតាមរូបភាពពីរយ៉ាងគឺៈ (១) តាមរូបភាពក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និង (២) តាមរូបភាពចំការដំណាំគ្រួសារ។

២. ទោះបីជាព្រៃសម្បទាននៅទូទាំងប្រទេសបានលុបចោលស្ទើរតែទាំងស្រុងជាយូរមកហើយក្តី តែគំរបព្រៃ និងដំណុះឡើងវិញរបស់ព្រៃពុំមានលក្ខណៈប្រសើរឡើងទេ។ ក្នុងខណៈដែលច្បាប់ និងសារាចរណ៍ជាច្រើនបានបង្កើតឡើងក្នុងគោលបំណងធ្វើយ៉ាងណាដើម្បីធានាបាននូវចីរភាពបរិស្ថាន ប៉ុន្តែជាក់ស្តែងយើងគួរតែហ៊ានទទួលស្គាល់ថា យន្តការនៃការអនុវត្តន៍ទាំងឡាយនោះនៅពុំទាន់មានប្រសិទ្ធិភាពគ្រប់គ្រាន់ដើម្បីទប់ស្កាត់សកម្មភាពលួចឆ្លក់ពីសំណាក់ជនឱកាសនិយម និងតំរូវការដើម្បីការរស់នៅរបស់សហគមន៍មូលដ្ឋានបានឡើយ។ ហើយអ្វីដែលជាកង្វល់គឺ ធនធានព្រៃឈើទាំងនោះបាននឹងកំពុងតែបន្តបាត់បង់ទៅដោយទាំងពុំបានផ្តល់ចំណូលដល់ថវិកាជាតិ ចំណែកឯសហគមន៍មូលដ្ឋានខ្លួនឯងក៏កាន់តែក្រីក្រទៅៗ ដោយការប្រឈមមុខជាមួយនឹងអន្តរកម្មរវាងភាពក្រីក្រ និងការរេចរឹលផ្នែកបរិស្ថាន និងភាពព្រងើយកន្តើយមិនអើពើចំពោះភាពចាំបាច់ផ្នែកសេដ្ឋកិច្ច ដែលជាលទ្ធផលអាចនាំឱ្យឈានទៅដល់ស្ថានភាពអូសបន្លាយមួយ ក្នុងនោះសហគមន៍ទាំងឡាយនោះអាចនឹងបំផ្លាញឬធ្វើឱ្យខ្សោះដោយអចេតនានូវធនធានដ៏ផុយស្រួយ ដែលពួកគាត់កំពុងតែពឹងផ្អែកប្រាស្រ័យសម្រាប់ការរស់នៅរបស់ពួកគាត់។

៣. ជាមួយនឹងអន្តរកម្មរវាងភាពក្រីក្រនិងការរេចរឹលផ្នែកបរិស្ថាននេះ វាបាននឹងកំពុងតែធ្វើឱ្យល្បឿននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចថយចុះយ៉ាងស្ងប់ស្ងាត់ ដោយសារតម្រូវឱ្យមានការបង្កើនខ្ទង់ថវិកានៃឆ្នាំសារពើពន្ធទៅលើកម្មវិធីសេវាកម្មសុខាភិបាល ការស្តារឡើងវិញនូវការធ្លាក់ចុះនៃផលិតភាពកសិកម្ម និងការស្តារឡើងវិញនូវធនធានធម្មជាតិផងដែរ។

៤. ជាការពិតណាស់ដែលថាសកម្មភាពអភិវឌ្ឍន៍ទាំងនេះ ទោះតិចក្តីច្រើនក្តី តែងតែប៉ះពាល់លើធនធានធម្មជាតិ និងជីវភាពរស់នៅរបស់ប្រជាជនក្នុងសហគមន៍មូលដ្ឋាន ដូច្នេះហើយទើបគំរោងអភិវឌ្ឍន៍ទាំងនេះត្រូវបានយកចិត្តទុកដាក់ឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានឱ្យបានច្បាស់លាស់។

៥. នៅក្នុងស្ថានភាពដែលយើងកំពុងតែដឹង និងមើលឃើញថា ធនធានព្រៃឈើកាន់តែរេចរឹលខ្សត់ទៅៗ ដោយសារចរន្តនៃការចំរាញ់យកផលពីសំណាក់ជនឱកាសនិយម និងការបន្តនូវប្រពៃណីផ្អែកផ្ទួលរបស់ប្រជាជន

Draft

សហគមន៍ទៅលើធនធានទាំងនោះ យើងគួរតែបង្វែរចក្ខុវិស័យទៅលើវិធីសាស្ត្រប្រសិទ្ធិភាពនៃការប្រើប្រាស់ដី នៅក្នុងជម្រើសផ្សេងទៀត តាមរយៈការប្រែក្លាយពីតំបន់ព្រៃរេចរឹល ឬព្រៃដែលមានតំលៃពាណិជ្ជកម្មទាប ទៅជាតំបន់អភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មជាមួយនឹងការរៀបចំផែនការប្រើប្រាស់ និងគ្រប់គ្រងដីឱ្យបាន សមស្រប ដោយផ្សារភ្ជាប់ជាមួយនឹងវិធានការបរិស្ថាន ក្នុងនោះការកាត់បន្ថយក្នុងកំរិតអតិបរមានូវហេតុប៉ះពាល់អវិជ្ជមានទៅលើបរិស្ថានរយៈពេលខ្លី និងវែងហើយនឹងការយកចិត្តទុកដាក់ចំពោះបញ្ហាសហគមន៍នៅក្នុងក្របខ័ណ្ឌមួយដែលមានតម្លាភាព និងគណនីយភាពត្រឹមត្រូវច្បាស់លាស់នោះ វានឹងនាំមកនូវប្រសិទ្ធិភាពសេដ្ឋកិច្ចខ្លាំងថែមទៀតជាក់ជាមិនខាន។

៦. ជាការពិតណាស់ដែលថា នៅពេលដែលយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍បានប្រែក្លាយតំបន់មួយទៅជាតំបន់កសិ-ឧស្សាហកម្មហើយនោះ អ្វីដែលជាអត្ថប្រយោជន៍សំរាប់ប្រជាជនមូលដ្ឋានគឺ ការនាំមកនូវវិបុលភាពជាក់លាក់មួយនៅក្នុងសង្គមជនបទ ព្រោះថានៅពេលដែលឱកាសនៃការផ្តល់ការងារដល់កម្មករមានសន្ទុះកើនឡើងកំរិតនៃផលចំណូលគ្រួសារក៏មានលក្ខណៈល្អប្រសើរទៅតាមនោះដែរ។ ជាលទ្ធផល កំណើននៃលទ្ធភាពទិញដូរនឹងជំរុញឱ្យមានភាពសកម្មនូវចរន្តសេដ្ឋកិច្ចនៅក្នុងតំបន់តាមរយៈការបំពេញសេចក្តីត្រូវការទំនិញ និងសេវាកម្មផ្សេងៗរបស់សហគមន៍។

៧. ក្នុងពេលដែលសង្គម និងបរិស្ថានមានការផ្លាស់ប្តូរស្របគ្នាជាមួយនឹងដំណើរការនៃការអភិវឌ្ឍន៍ជាវិជ្ជមាននោះ វាក៏ជាកត្តាមួយដែលអាចបណ្តាលឱ្យមាននូវជម្លោះផ្សេងៗផងដែរ។ ដូច្នេះដើម្បីសំរេចបាននូវឆន្ទៈនយោបាយក្នុងការអភិវឌ្ឍន៍ដំណាំកសិកម្ម និងដំណាំកសិ-ឧស្សាហកម្ម គឺផ្អែកលើទស្សនាទានសង្គម-បរិស្ថាននិងសេដ្ឋកិច្ច។ ការរៀបចំនូវឯកសារបទដ្ឋានបច្ចេកទេស (ផែនការពិស្តារ និងផែនការប្រតិបត្តិប្រចាំឆ្នាំនីមួយៗ ការគណនាអំពីភាពស្ថិតស្ថេរផ្នែកសេដ្ឋកិច្ច របាយការណ៍វាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាននិងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន) គឺជាចំណុចគន្លឹះសំរាប់ក្រុមការងារអន្តរស្ថាប័នពាក់ព័ន្ធ ក្នុងការប្រើជាឧបករណ៍សំរាប់តាមដានត្រួតពិនិត្យ-វាយតំលៃទៅលើរាល់សកម្មភាព និងសុច្ចនាករនានា ដែលអាចធានាបានថារាល់សកម្មភាពនៃការអភិវឌ្ឍន៍គំរោង ពិតជាឆ្លើយតបទៅនឹងទស្សនាទានសង្គម-បរិស្ថាន និងសេដ្ឋកិច្ច។

## ១-១ គោលបំណង

៨. តួនាទីចំបង និងគោលបំណងនៃការប្រើប្រាស់ដីរបស់ក្រុមហ៊ុន **TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.** គឺធ្វើយ៉ាងណាដើម្បីធានាបាននូវចីរភាពនៃការដាំដំណាំកៅស៊ូ។ តែទោះជាយ៉ាងនេះក្តី ព្រៃឈើក៏មានតួ នាទីជាអ្នករក្សាសុវត្ថិភាពដល់ភារៈទូទៅរបស់អេកូឡូស៊ីបរិស្ថាន និងសង្គមផងដែរ នៅពេលដែលយើងគ្រប់គ្រងបានត្រឹមត្រូវ។ ដូច្នេះគោលបំណងនៃការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងគឺ:

ក-វាយតំលៃអំពីស្ថានភាពអេកូឡូស៊ីរបស់រុក្ខជាតិក្នុងពេលបច្ចុប្បន្ន (រុក្ខជាតិ ជុល្លព្រឹក្ស តិណជាតិ)។

ខ- វាយតំលៃអំពីស្ថានភាពអេកូឡូស៊ីរបស់សត្វ (ថនិកសត្វ បកុណជាតិ បក្សី និងឧរង្គសត្វ) និងជីវិតសត្វរស់នៅក្នុងទឹក (ពពួកត្រី) នៅតាមប្រព័ន្ធអូរសំខាន់ៗ។

គ-វាយតំលៃអំពីស្ថានភាពសង្គម សេដ្ឋកិច្ចរបស់សហគមន៍មូលដ្ឋានក្នុងពេលបច្ចុប្បន្ន

ឃ-កំណត់អំពីបញ្ហាហេតុប៉ះពាល់បរិស្ថាន-សង្គមអវិជ្ជមានសំខាន់ៗ ដែលបណ្តាលមកពីសកម្មភាពគំរោងអភិវឌ្ឍន៍ដាំដំណាំកៅស៊ូ។

ង- កំណត់នូវវិធានការណ៍សមស្របដើម្បីលុបបំបាត់ និង/ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានរបស់គំរោងអភិវឌ្ឍន៍ដំណាំកៅស៊ូ។

## ១-២ វិធីសាស្ត្រស្រាវជ្រាវ

**៩.** ដើម្បីសំរេចបាននូវគោលបំណងខាងលើ Green Consultancy Firm បានធ្វើការវាយតំលៃដោយប្រើនូវវិធីសាស្ត្រស្រាវជ្រាវដូចមានបង្ហាញជូនខាងក្រោម:

ក- លក្ខណៈជីវៈរូបសាស្ត្រ: ប្រើប្រាស់ទិន្នន័យរបស់ស្ថានីយ៍ឧតុនិយម (ទិន្នន័យសីតុណ្ហភាព ២០០០-២០០៩ និង កំពស់ទឹកភ្លៀង ២០០០-២០០៩ នៅស្ថានីយ៍ឧតុនិយមខេត្តកំពង់ធំ)។

ខ- បំរែបំរួលការប្រើប្រាស់ដី និងគំរបព្រៃ : ប្រើប្រាស់ទិន្នន័យ (MRC Dataset 1992-1993; MRC Dataset 1996-1997 ; FA GIS Dataset 2002 ; and FA GIS Dataset 2006) និងការអង្កេតជាក់ស្តែង នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១១ ដោយប្រើឧបករណ៍ paramotor លើគន្លងឆ្លងកាត់ចម្ងាយ ២៥គ.ម គ្របដណ្តប់លើផ្ទៃដី ៨៦៥ហិកតា ស្មើនឹង ១០,៦៨ ភាគរយ ក្នុងរយៈកំពស់ ៦០០ម. ថតយករូបភាពច្បាស់ ចាប់ទំហំ ០,៣ ម. ឡើងទៅ។

គ- ការសិក្សាអំពីភាពសម្បូរណ៍បែបរបស់រុក្ខជាតិ ជុល្លព្រឹក្ស តិណជាតិ ត្រូវបានធ្វើឡើងតាមរយៈការអង្កេតនូវប្រភេទនៃសារព័ន្ធរុក្ខជាតិ ដែលយើងអាចសង្កេតឃើញមាននៅក្នុងឡូត៍គំរូចំនួន១៧ ក្នុងនោះ ១១ឡូតិ៍ ស្ថិតក្នុងចំការកៅស៊ូ និងដីល្បូសឆាយហើយមិនទាន់ដាំ និង០៦ទៀតស្ថិតក្នុងតំបន់រក្សាទុក (តំបន់ទ្រនាប់បំរុងទុកស្តារព្រៃឡើង វិញតែប៉ុណ្ណោះ (ឧបសម្ព័ន្ធ១-២ និងរូបភាព Eye view-1, Photo-Index K, L, M, Oនិង P (ឧបសម្ព័ន្ធ ៤-៦) តាមគន្លងឆ្លងកាត់ចម្ងាយ ៣១,២៧ គ.ម កាលពីថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១១ និងថ្ងៃទី១៨-២០ ខែ កក្កដា ឆ្នាំ២០១១ របស់ក្រុមការងារអង្កេតអេកូឡូស៊ី (ឧបសម្ព័ន្ធ ១-២)។

**១០.** ការវាយតំលៃលើធនធានសង្គម-វប្បធម៌: ការសិក្សាអំពីស្ថានភាពសង្គមសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋក្នុងឃុំក្រយា ស្រុកសន្ទុក ដោយប្រើវិធីសាស្ត្រ Qualitative Method ដោយការធ្វើ PRA តាមរយៈការធ្វើអត្ថាធិប្បាយសង្ខេប អំពីហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមានទៅលើបញ្ហាបរិស្ថាន និងសង្គម-សេដ្ឋកិច្ច និងមាន

Draft

ការចូលរួមពី ឯកឧត្តមអភិបាលរងខេត្តកំពង់ធំ នាយករដ្ឋបាលសាលាខេត្ត នាយរងទីចាត់ការអន្តរវិស័យ អនុប្រធានមន្ទីរបរិស្ថានខេត្តកំពង់ធំ អនុប្រធានមន្ទីរដែនដីនគររូបនីយកម្ម និងសំណង់ នាយផ្នែករដ្ឋបាលព្រៃឈើខេត្តកំពង់ធំ អភិបាលរងស្រុកសន្ទុក មន្ត្រីការិយាល័យផែនការ នៃមន្ទីរកសិកម្មខេត្ត អនុការិយាល័យកសិកម្ម នៃមន្ទីរកសិកម្មខេត្ត សរុបចំនួន ០៩នាក់ កាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១១ នៅសាលាខេត្តកំពង់ធំ និង លោកអភិបាលស្រុកសន្ទុក មេឃុំក្រយា ស្មៀនឃុំក្រយា សរុបចំនួន ៣នាក់ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០១១។

## ១-៣ ក្រុមការងារ GCF

១១. ក្រុមការងារវាយតំលៃហេតុប៉ះពាល់បរិស្ថានមានចំនួន០៨នាក់ ដឹកនាំដោយ **បណ្ឌិត លី សុពណ៌-មុនី** (នាយក) ដូចមានរាយនាមខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- | បណ្ឌិត | លី សុពណ៌-មុនី | D.V.M. Post Ph.D. |
| ២- | អនុបណ្ឌិត | តេង ប៉េងសៀង | GIS & RS Specialist |
| ៣- | បរិញ្ញាត្រី | ឆាយ ងួន | ជំនាញការផ្នែកផែនទី |
| ៤- | បរិញ្ញាត្រី | គី សារ៉េត | ជំនួយការក្រុមហោះហើរ |
| ៥- | បរិញ្ញាត្រី | ឡៅ សាវុន | អ្នកប្រមូលទិន្នន័យផ្នែកសង្គម-សេដ្ឋកិច្ច |
| ៦- | បរិញ្ញាត្រី | នន ណារ៉ុង | អ្នកប្រមូលទិន្នន័យផ្នែកសង្គម-សេដ្ឋកិច្ច |
| ៧- | បរិញ្ញាត្រី | អ៊ុន ចាន់ណារ៉ូ | អ្នកប្រមូលទិន្នន័យផ្នែកសង្គម-សេដ្ឋកិច្ច |
| ៨- | បរិញ្ញាត្រី | នួន ចំណាប់ | អ្នករៀបចំផែនទី |

Draft